**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៥. ០២១. ៩៤៣ ស.រ.ណ

ថ្ងៃ ពុធ ១០រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០២១

# សេចក្តីជូនដំណឹង
# ស្តីពី
# ការជ្រើសរើសបុគ្គលិក

ធនាគារជាតិនៃកម្ពុជា សូមជម្រាបជូនដំណឹងដល់សិស្ស និស្សិត និងសាធារណជន ឱ្យបានជ្រាបថា ធនាគារជាតិនៃកម្ពុជានឹងធ្វើការជ្រើសរើសបុគ្គលិកសម្រាប់ក្របខ័ណ្ឌមន្ត្រីក្រមការ "**ខ**" ទាំងពីរភេទ ចំនួន **២៥**រូប ដើម្បីចូលបម្រើការងារនៅធនាគារជាតិនៃកម្ពុជា។

បេក្ខជនទាំងពីរភេទត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

១/. មានសញ្ជាតិខ្មែរ
២/. មានអាយុច្រើនបំផុត ៣០ឆ្នាំ គិតត្រឹមថ្ងៃឈប់ទទួលពាក្យ
៣/. មានសញ្ញាបត្របរិញ្ញាបត្រផ្នែកព័ត៌មានវិទ្យា ឬជំនាញបច្ចេកទេសពាក់ព័ន្ធ
៤/. មានចំណេះដឹងភាសាអង់គ្លេស
៥/. មានសុខភាពល្អ
៦/. បេក្ខជនត្រូវមានចំណេះដឹង និងបទពិសោធន៍ការងារពាក់ព័ន្ធនឹង៖

**ក. ផ្នែកអភិវឌ្ឍន៍កម្មវិធី (Software Development) សរុប ១២រូប៖**

- មានជំនាញ និងបទពិសោធន៍សរសេរកម្មវិធី Java & Python Programming
- មានចំណេះដឹង និងបទពិសោធន៍អភិវឌ្ឍន៍ Mobile Application ដូចជា Apple iOS និង Android Application
- មានជំនាញ និងបទពិសោធន៍គ្រប់គ្រង Oracle Database និង Database
- មានជំនាញ និងបទពិសោធន៍ផ្នែក User Interface/User Experience (UI/UX) Design
- មានជំនាញ និងបទពិសោធន៍ផ្នែក Design Report (Oracle BI, Crystal Report)។

**ខ. ផ្នែកគ្រប់គ្រងប្រព័ន្ធបណ្តាញ (Network Management) សរុប ០៤រូប៖**

- មានជំនាញ និងបទពិសោធន៍គ្រប់គ្រងម៉ាស៊ីនកុំព្យូទ័រមេ ប្រព័ន្ធបណ្តាញកុំព្យូទ័រ និងឧបករណ៍បណ្តាញ (Cisco, FORTIGATE)
- មានជំនាញ និងបទពិសោធន៍លើប្រព័ន្ធប្រតិបត្តិការ Linux និង Unix, DevOps Docker, Docker Compose, Docker Swarm, និង Kubernetes



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

- មានជំនាញថែទាំ និងដំឡើងប្រព័ន្ធកាមេរ៉ាសុវត្ថិភាព និងជំនាញប្រព័ន្ធអគ្គិសនី ។

**គ. ផ្នែកគាំទ្រប្រព័ន្ធទូទាត់ (Payment System Support) សរុប ០៥រូប៖**

- មានជំនាញអភិវឌ្ឍន៍កម្មវិធី និងបទពិសោធន៍គាំទ្រការងារប្រព័ន្ធទូទាត់
- មានជំនាញ និងបទពិសោធន៍ផ្នែក Graphic Design និង Video Editing
- មានជំនាញ និងបទពិសោធន៍ផ្នែកទីផ្សារ (Promotion and Marketing)។

**ឃ. ផ្នែកគ្រប់គ្រងកម្មវិធី (Application Management) សរុប ០២រូប៖**

- មានជំនាញគណនេយ្យ និងអាជីវកម្ម (Accounting and Business)
- មានចំណេះដឹងផ្នែករៀបចំរបាយការណ៍ក្នុងប្រព័ន្ធធនាគារ (Oracle BI) និងបទពិសោធន៍លើភាសា SQL/PLSQL (Oracle)។

**ង. ផ្នែកសុវត្ថិភាពព័ត៌មានវិទ្យា (Information Security) សរុប ០២រូប៖**

- មានជំនាញ និងបទពិសោធន៍ក្នុងការធ្វើតេស្តលើកម្មវិធី និងប្រព័ន្ធក្នុងន័យពង្រឹងគុណភាពកម្មវិធី (Software Testing and Quality Assurance) ។

បេក្ខជនអាចមកទំនាក់ទំនងសាកសួរព័ត៌មានលម្អិតបន្ថែមទៀត នៅនាយកដ្ឋានបុគ្គលិក នៃធនាគារជាតិនៃកម្ពុជា ដែលមានទីតាំងនៅភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ចន្លោះពីម៉ោង ៨:០០ព្រឹក ដល់ម៉ោង ១៥:០០ រសៀល រៀងរាល់ថ្ងៃធ្វើការ ឬតាមរយៈលេខទូរសព្ទ ០២៣ ៧២២ ៥៦៣។

- កាលបរិច្ឆេទទទួលពាក្យប្រឡង ៖ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ
- កាលបរិច្ឆេទឈប់ទទួលពាក្យប្រឡង ៖ ថ្ងៃសុក្រ ទី១៤ ខែមករា ឆ្នាំ២០២២ វេលាម៉ោង ១១:០០នាទី
- កាលបរិច្ឆេទ មុខវិជ្ជា និងទីកន្លែងប្រឡង ៖ ជូនដំណឹងពេលក្រោយ ។

**ត.ប.ទេសាភិបាល**
**អគ្គលេខាធិការ**

ឌុំ ចាន់តារា